# ខ្មែរអន់

១.　ខ្មែរអន់ចូលចិត្ត ជនរណប　ក្លេបក្លុបក្លេមក្លើម អើមអើតអោយ
លុតក្រាបលន់តួរ ជូនដង្វាយ　បើខ្លាំងបរិយាយ ខ្ចីតែហោង ។
២.　ខ្មែរអន់ចូលចិត្ត អ្នកសរសើរ　រួចអាលនឹងប្រើ មិនមើលម៉ោង
បើមិនព្រមត្រាប់ នឹងត្រូវថ្នោង　វាយវាត់អោយប៉ោង បែកសាច់ឈាម ។
៣.　ខ្មែរអន់ចូលចិត្ត ធ្វើចៅហ្វាយ　ទោះខ្ចីមិនឆ្ងាយ គិតមិនឈ្មៀម
អោយតែអ្នកផង ព្រមធ្វើចៀម　នៅស្ងៀមកុំត ត្រូវទាំងអស់ ។
៤.　ខ្មែរអន់ចូលចិត្ត អោយតំកើង　បញ្ចើចលើកជើង ដើម្បីផ្លោះ
ហក់លោតប្រណាំង តាំងសម្រស់　ដើម្បីបានឆ្ពោះ ទៅដូចចិត្ត ។
៥.　ខ្មែរអន់ចូលចិត្ត តាំងខ្លួនខ្ពស់　ដិកល់កេរ្តិ៍ឈ្មោះ ហួសការពិត
អោយគេគោរព ឬប្រតិបត្តិ　ពុំដែលចេះគិត ខ្មាស់អ្នកផង ។
៦.　ខ្មែរអន់ចូលចិត្ត អោយគេកោត　ទោះខ្លួនល្ងង់ឆោត ឥតគន្លង
ក៏មានមោទនៈ ដូចយូកូង　អួតអាងអ្នកផង តាំងខ្លួនគ្រាន់ ។
៧.　ខ្មែរអន់ចូលចិត្ត ជឿផ្កាប់មុខ　អស់ស្រូវជង្រុក ក៏នៅបន់
ជឿខ្មោចអារ័ក្ស ធាក់បញ្ជាន់　មិនគិតឃ្មេឃ្មាន់ អោយរលាយ ។
៨.　នេះគឺខ្មែរអន់ ចរឹកថោក　មិនចេះលៃលក រៀនស្វាធ្យាយ
ចេះត្រឹមលាក់ក្បួន ក្នុងសំពាយ　ស្រែកពពាយនាយ លក់ពេញស្រុក.......... ។

**ដោយៈ　ដែនដីសេរីភាព**